# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1221

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងធ្វើឱ្យប្រសើរឡើងនូវឧស្សាហកម្មពាណិជ្ជកម្មក្នុងវិស័យភ័ស្តុភារកម្ម និងការអនុវត្តគម្រោងសាកល្បង

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 01/01/27 |
| ៣. ចំណាយគម្រោងសរុប | $2,200,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| RESPONSIBLE UNIT | General Department of Logistics |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានភ័ស្តុភារកម្ម |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ស្វែងរកម្ចាស់ជំនួយ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការអភិវឌ្ឍធនធានមនុស្សនិងការពង្រឹងស្ថាប័នតាមរយៈអនុវត្តការងារសម្របសម្រួល និងការរៀនសូត្រដោយការអនុវត្តជាមួយនឹងគម្រោងដែលបានស្នើសុំនេះ។ ការរៀបចំឯកសារ និងរបាយការណ៍នៃការរកឃើញសំខាន់ៗ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តគម្រោងនៃការណែនាំអំពីប្រព័ន្ធដាក់ចំណាត់ថ្នាក់នៅក្នុងឧស្សាហកម្មភ័ស្តុភារកម្ម ឱ្យមានអំណោយផលបរិស្ថាន និងការប្រកួតប្រជែងដោយយុត្តិធម៌ទៅលើការអភិវឌ្ឍវិស័យភ័ស្តុភារកម្ម និងសម្រាប់អ្នកផ្តល់សេវាកម្មភ័ស្តុភារកម្ម។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

ការដឹកជញ្ជូន Logistics

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

គ្រប់ខេត្តក្រុង,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

គម្រោងនេះមានគោលបំណងវិភាគការអនុវត្តបច្ចុប្បន្នរបស់ឧស្សាហកម្មពាណិជ្ជកម្មក្នុងវិស័យភ័ស្តុភារកម្មនៅប្រទេសកម្ពុជា និង
បង្កើតគោលការណ៍ណែនាំអំពីប្រព័ន្ធចំណាត់ថ្នាក់ដើម្បីជួយអោយមានការរីកចម្រើន
និងពង្រឹងឧស្សាហកម្មពាណិជ្ជកម្មក្នុងវិស័យភ័ស្តុភារកម្ម។ គោលបំណងសំខាន់ៗ នៃគម្រោងស្នើសុំនេះ រួមមាន៖
• រៀបចំសិក្សាអំពីការអនុវត្តបច្ចុប្បន្នក្នុងការងារភ័ស្តុភារកម្មរបស់ពាណិជ្ជកម្មភ័ស្តុភារកម្ម និងសេវាភ័ស្តុភារកម្មនៅប្រទេសកម្ពុជា
- រៀបចំបង្កើតគោលការណ៍ណែនាំអំពីវិញ្ញាបនប័ត្រនៃប្រព័ន្ធចំណាត់ថ្នាក់
ដែលពាក់ព័ន្ធនឹងសេវាភ័ស្តុភារកម្មក្នុងវិស័យភ័ស្តុភារកម្មនៅប្រទេសកម្ពុជា
- កសាងសមត្ថភាព និងការលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធសម្រាប់វិស័យសាធារណៈ
និងឯកជនក្នុងវិស័យឧស្សាហកម្មភ័ស្តុភារកម្មតាមរយៈកម្មវិធីសិក្សាក្នុងសាលា, ការបណ្តុះបណ្តាល
និងការផ្លាស់ប្តូរទស្សនកិច្ចទៅប្រទេសទីបី
- រៀបចំអនុវត្តគម្រោងសាកល្បង។

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

• រៀបចំការសិក្សាវាយតម្លៃ
- ការប្រមូលទិន្នន័យ និងស្ទង់មតិរបស់ដៃគូពាក់ព័ន្ធនៅក្នុងវិស័យភ័ស្តុភារកម្ម
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធសំខាន់ៗ ដើម្បីប្រមូលធាតុចូល និងមតិយោបល់
- រៀបចំរបាយការណ៍ផ្ទៃក្នុងចុងក្រោយនៃការស្ទង់មតិ
- បោះពុម្ពរបាយការណ៍ចុងក្រោយនៃការស្ទង់មតិ និងផ្សព្វផ្សាយលទ្ធផលរបាយការណ៍ក្នុងសិក្ខាសាលា
• រៀបចំបង្កើតគោលការណ៍ណែនាំអំពីប្រព័ន្ធចំណាត់ថ្នាក់ និងការណែនាំប្រព័ន្ធចំណាត់ថ្នាក់ភ័ស្តុភារកម្ម
- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំអំពីប្រព័ន្ធចំណាត់ថ្នាក់ភ័ស្តុភារកម្ម
-
ពិនិត្យមើលសេចក្តីព្រាងគោលការណ៍ណែនាំអំពីប្រព័ន្ធចំណាត់ថ្នាក់ភ័ស្តុភារកម្មជាមួយដៃគូពាក់ព័ន្ធនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ឬការប្រជុំ
- រៀបចំបញ្ចប់ និងអនុម័តគោលការណ៍ណែនាំអំពីប្រព័ន្ធចំណាត់ថ្នាក់ភ័ស្តុភារកម្ម
- អនុវត្តគម្រោងសាកល្បង និងណែនាំអំពីប្រព័ន្ធចំណាត់ថ្នាក់ភ័ស្តុភារកម្មជាមួយសាជីវកម្ម
និងក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងសេវាកម្មភ័ស្តុភារកម្ម
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ
• កសាងសមត្ថភាព និងការលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធសម្រាប់វិស័យសាធារណៈ និងឯកជន
- កម្មវិធីអាហារូបករណ៍គោលដៅ៖ សិស្សក្រីក្រនិង / ឬសិស្សងាយរងគ្រោះ (១០ នាក់), វិស័យសាធារណៈ
និងឯកជនដែលចូលរួមក្នុងឧស្សាហកម្មពាណិជ្ជកម្មភ័ស្តុភារកម្ម
- កម្មវិធីកម្មសិក្សា៖ សហការជាមួយក្រុមហ៊ុនភ័ស្តុភារកម្ម ដើម្បីរៀបចំកម្មវិធីកម្មសិក្សាសម្រាប់និស្សិតអាហារូបករណ៍
- ការបណ្តុះបណ្តាលផ្ទៃក្នុង៖ អ្នកចូលរួម ២៥ នាក់ដែលមកពីវិស័យសាធារណៈ និងឯកជន
- ការបណ្តុះបណ្តាលនៅក្រៅប្រទេស៖ ១០ នាក់ (រួមបញ្ចូលទាំងអគ្គនាយកនៃអគ្គនាយកដ្ឋានភ័ស្តុភារកម្ម
និងដៃគូសំខាន់ៗមកពីវិស័យឯកជនដែលពាក់ព័ន្ធនឹងវិស័យភ័ស្តុភារកម្ម)
- ការផ្លាស់ប្តូរទស្សនកិច្ច៖ ក្នុងប្រទេស និងក្រៅប្រទេស
- រយៈពេលនៃការបណ្តុះបណ្តាលក្រៅប្រទេស៖ ៧ថ្ងៃ ២ដង, (៦ដង ក្នុងអំឡុងពេលនៃគម្រោង)
• រៀបចំគម្រោងសាកល្បង
- រៀបចំណែនាំអំពីគោលការណ៍ណែនាំ និងប្រព័ន្ធចំណាត់ថ្នាក់ភ័ស្តុភារកម្មជាមួយសាជីវកម្ម
និងក្រុមហ៊ុនដែលពាក់ព័ន្ធក្នុងសេវាកម្មភ័ស្តុភារកម្មសំរាប់ការទទួលយកវិញ្ញាបនប័ត្រ
- ផ្តល់អាហារូបករណ៍ដល់បេក្ខជនដែលបានជ្រើសរើសចំនួន ១០
នាក់ដើម្បីទៅសិក្សានៅសាកលវិទ្យាល័យដែលបានជ្រើសរើសនៅប្រទេសកម្ពុជា និង / ឬប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

• ដោយសារតែមានការបង្កើតក្រុមប្រឹក្សាជាតិភ័ស្តុភារកម្ម និងគណកម្មាធិការជាតិភ័ស្តុភារកម្ម
ដែលមានអគ្គ-នាយកដ្ឋានភ័ស្តុភារកម្មជាលេខាធិការដ្ឋាន ជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការជម្រុញការអភិវឌ្ឍវិស័យភ័ស្តុភារកម្ម
ហើយសមត្ថភាពគ្រប់គ្រងរបស់អគ្គនាយកដ្ឋានភ័ស្តុភារកម្ម តម្រូវឱ្យមានការពង្រឹងសមត្ថភាពបន្ថែម
ដើម្បីឱ្យការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព
•
ដោយក្នុងផែនការមេភស្តុភារកម្មមានការដាក់បញ្ចូលគម្រោងការធ្វើអោយប្រសើរឡើងនូវឧស្សាហកម្មពាណិជ្ជកម្មក្នុងវិស័យភ័ស្តុភារកម្ម
និងការអនុវត្តគម្រោងសាកល្បង គម្រោងនេះនឹងចូលរួមចំណែកដល់ការសម្រេចបាននូវការអនុវត្តគម្រោង
និងជាពិសេសដើម្បីកំណត់ធាតុចូលសំខាន់ៗ សម្រាប់គម្រោង
• ស្របតាមសកម្មភាពកើនឡើងនៃសេដ្ឋកិច្ច ការពង្រីកសេវាកម្មភ័ស្តុភារកម្មចម្រុះ
និងការរីកចម្រើននៃឧស្សាហកម្មភស្តុភារកម្មនឹងកើតឡើងនៅក្នុងប្រទេសកម្ពុជានាពេលខាងមុខ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

ជារួមគម្រោងនឹងមានអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចចំពោះអ្នកទទួលផលនីមួយៗដូចខាងក្រោម៖

• ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងអាចដោះស្រាយបញ្ហា និងកែលំអប្រសិទ្ធភាព និងការប្រកួតប្រជែងនៃឧស្សាហកម្ម

• ពាណិជ្ជកម្មក្នុងវិស័យភ័ស្តុភារកម្ម ក្នុងការធ្វើផែនទីបង្ហាញផ្លូវ
នៃការអនុវត្តគម្រោងដែលបានគូសបញ្ជាក់ផងដែរក្នុងផែនការមេភ័ស្តុភារកម្ម

• ប្រាក់ចំណូលរបស់រដ្ឋាភិបាលនឹងត្រូវបានកើនឡើងតាមរយៈពន្ធ និងពន្ធនាំចេញ នាំចូល
ហើយលក្ខណៈល្អនេះគឺដោយសារតែភាពប្រសើរឡើងនូវការសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសពាណិជ្ជកម្មភ័ស្តុភារកម្ម

•
ទីភ្នាក់ងារពាក់ព័ន្ធផ្សេងទៀតរបស់រដ្ឋាភិបាលអាចប្រើប្រាស់របាយការណ៍លទ្ធផលនៃគម្រោងនេះជាឯកសារយោងសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន

• ភ្នាក់ងារសាធារណៈ និងឯកជនអាចពង្រឹងសមត្ថភាព ធនធានមនុស្សទាំងជំនាញ និងចំណេះដឹងទាក់ទងនឹងពាណិជ្ជកម្ម

• ភ័ស្តុភារកម្ម និងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់តាមរយៈកម្មវិធីអាហារូបករណ៍ និងកម្មសិក្សា

• អ្នកផ្តល់សេវាកម្មភ័ស្តុភារ
និងទីភ្នាក់ងារពាក់ព័ន្ធអាចទទួលបានអត្ថប្រយោជន៍តាមរយៈវត្តមាននៃដំណាក់កាលបន្ទាប់នៃការអនុវត្តការការធ្វើអោយប្រសើរឡើងនូវឧស្សាហកម្មពាណិជ្ជកម្មក្នុងវិស័យភ័ស្តុភារកម្ម

• និស្សិតក្នុងគ្រួសារងាយរងគ្រោះ
ឬនិស្សិតក្រីក្រនឹងអាចទទួលយកនូវកម្មវិធីអាហារូបករណ៍ដែលជាការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទានចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះនឹងមិនមានសកម្មភាពណាមួយ ដែលនឹងជះឥទ្ធិពលអវិជ្ជមានដល់សង្គម និង/ឬ បរិស្ថានឡើយ។ ផ្ទុយទៅវិញ
គម្រោងនេះនឹងជះឥទ្ធិពលវិជ្ជមាននិងប្រយោលទៅលើសង្គម
និងសេដ្ឋកិច្ចតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការតាមដាននិងវាយតម្លៃវិស័យភស្តុភារកម្ម
ដើម្បីផ្តល់នូវអនុសាសន៍សមស្របនិងជាក់ស្តែងដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យភ័ស្តុភារកម្មនៅកម្ពុជា។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

តុល្យភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនឹងត្រូវយកចិត្តទុកដាក់នៅក្នុងគម្រោងនេះ។
គម្រោងនេះនឹងលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រីក្នុងវគ្គបណ្តុះបណ្តាលនិងសកម្មភាពតាមដាននិងវាយតម្លៃលើវិស័យកំស្តភារកម្ម

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្រសួងមានអ្នកជំនាញដែលមានជំនាញនិងបទពិសោធន៍ខ្លះៗ
ប៉ុន្តែអ្នកឯកទេសអន្តរជាតិតម្រូវឱ្យមានការជួយផ្ទេរជំនាញនិងចំណេះដឹង
ដើម្បីពន្លឿនប្រសិទ្ធភាពនៃការតាមដាននិងវាយតម្លៃលើវិស័យកំស្តភារកម្ម។

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

20

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

កំពុងស្វែងរកម្ចាស់ជំនួយ

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លាអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្នើ | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 100.0 | 120.0 | 120.0 | 340.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 100.0 | 120.0 | 120.0 | 340.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 520.0 | 620.0 | 720.0 | 1,860.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 170.0 | 170.0 | 170.0 | 510.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 50.0 | 50.0 | 50.0 | 150.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 300.0 | 400.0 | 500.0 | 1,200.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយសរុប | 0.0 | 0.0 | 0.0 | 620.0 | 740.0 | 840.0 | 2,200.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 620.0 | 740.0 | 840.0 | 2,200.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: